**សំណួរ ពាក់ព័ន្ធច្បាប់រដ្ឋធម្មនុញ្ញ (១)**

**តើរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ មានចែងអំពីសិទ្ធិដាច់ខាតដែរឬទេ (absolute right)?**

**ចម្លើយ**

តាមមាត្រា ៤ នៃកតិកាសញ្ញាស្តីពីសិទ្ធពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៦៧ សិទ្ធិមួយចំនួន មិនត្រូវបានផ្អាក ឬកម្រិតការគោរព និងការពារទេ ដូចជាសិទ្ធិរួចផុតពីអំពើទារុណកម្ម (right to freedom from torture) ។ វាមានន័យថា គ្មានបុគ្គលណាមួយ នឹងត្រូវបានធ្វើអំពើទារុណកម្ម ក្នុងអំឡុងពេលមានគ្រោះអាសន្នសាធារណៈ ដូចជាសង្គ្រាម ដោយសារហេតុផលបង្ក្រាបបទល្មើស។ សិទ្ធិប្រភេទនេះ ត្រូវគោរព និងការពារ ទាំងក្នុងពេលធម្មតា និងមានគ្រោះអាសន្ន(សូមមើលបន្ថែម សំណួរចម្លើយ អំពីសិទ្ធិដាច់ខាតនេះ)។

ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជំពូក ៣ ពីមាត្រា ៣១ ដល់៥០ បានចែងអំពីសិទ្ធិ និងកាតព្វកិច្ច។ មាត្រា ៣១ និយាយអំពីគោលការណ៍ទូទៅ ការទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ហើយក្នុងនោះ បានរំលេចនូវគោលការណ៍ មិនរើសអើង (non-discrimination) ព្រមទាំងសមាសភាគ នៃគោលការណ៍នីត្យានុកូល (principle of legality) (សូមមើលបន្ថែមសំណួរចម្លើយ នៃគោលការណ៍ទាំងពីរនេះបន្ថែម)។

ជំពូកទី៣នេះ ចែងអំពីសិទ្ធិជាច្រើនប្រភេទ ដូចជាសិទ្ធិផ្នែកស៊ីវិល (មាត្រា ៤០) នយោបាយ (មាត្រា ៣៤)សេដ្ឋកិច្ច (មាត្រា ៣៦) វប្បធម៌ (មាត្រា ៤៣) សិទ្ធិស្ត្រី (មាត្រា ៤៥) សិទ្ធិកុមារ (មាត្រា ៤៨) ព្រមទាំងសិទ្ធិពាក់ព័ន្ធនឹងយុត្តិធម៌ព្រហ្មទណ្ឌ (មាត្រា ៣២ និង ៣៨)ជាដើម។

មិនមានមាត្រាណាចែងស្រដៀងនឹងមាត្រា ៤ នៃកតិកា បង្ហាញថា សិទ្ធិណាមួយ ជាសិទ្ធិដាច់ខាតនោះទេ។